Khmer Story Lovers

# [illegible]

ប្រលោមលោកប្រឌិតតាមសម័យបុរាណ-ពិត

## ប្រលោមលោកបោះពុម្ពផ្សាយរៀងរាល់ថ្ងៃ



ចំនួនកូនក្រុមហ៊ុន១ ស្រែកប្រាប់ថា:

– លោកអើយ ! ក្រុមក្ដឹតកកកើតញ្ញាប់បនិងាន

ទៀតហើយ !

ចំនួនមិនហួសបញ្ញើម្នឹប:

-ឲ្យគេចាប់កាចក្នុងហ្គិនទៅសម្លាប់ចុះ, កុំឲ្យនៅ

ដើសមុខមើសមាត់គាយូរពេក ។

–កាឲ្យគេចាប់អាចក្នុងមួយណា? មនុស្សក្នុងគ្នាក

ប្ដូកល្ងង់ ។

–ឲ្យចាប់កន្ទុកផែលល្ងង់ខ្លៅ ហើយក្ដីភ្លើនោះណា!

ទៅចាប់មនុស្សផែលទ្វាគយកទៅធ្វើអី?

ចំនួនកុំនៅតែសើច:

–មែនហើយ ! មនុស្សក្នុងគាគមានគម្រុះខ្ពស់ណាស់,នរណា

ហ៊ានមកតាមទៅ?

ចំនួនមិនហួសបស្រមុំាំនកាំនបន្តិច ទើបឆ្លើយ:

-មិនទៅចាំថ្ងៃហ៊ានដេរពិតាផងឬ?

ពេលនេះចូកកួបកកាន់តែជិតហើយ ។ ចំនួនមិនហួសបិទិន

ចំនួនកុំនៅសៀមឡើព្រាតើយ ។ ផងពាក់កាសតាំនពីរូប

ស្រែកឡូឡាទៀតថា:

–អ្នកខាងមុខ ! កាក្មេងកូនកោះដូចកាចថ្ងៃស៊ីផុនយី ខាង

អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ ៣៖០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មារត្នភូមិ»
ភ្នំពេញ

លេខ ១៦

ត្អឹកកកណាស់, មើបមិនបង្អង់ទូកសិន ?

ស៊ឹផានរ៉ាកមើលទឹកភ្លៀងស្ងួរ:

-ទឹក១ភ្លៀង១មានគេដេញតាមទូកយើងហើយ, នាងគិតធ្វើម៉េចដែរ ?

-ខ្ញុំមិនដឹងទេ ! បងជាកូនប្រុស ម៉េចមិនចេះរកមធ្យោបាយការពារខ្លួន ?

ពេលនេះកូនទូកលួចកាត់ផ្លូវកបកជិតដល់ដងកាវសតីរនាក់ស្រែកឡូឡា ហើយលោតផ្លោះ ដល់កន្សៃទូកទីងមិនហួសបី, ត្រឹងាវចាំងភ្លើកមាណពព ។ ស៊ឹផានស្គាល់ជាក់ជាសិស្សត្អឹកកក នៅសំណាក់គុរុភោឆ័កញ្ចាស់ជាមួយជ្ញាំយរៀនជាន ។ នាយឆ្ងល់ណាស់ មិនដឹងខ្លួនប្រព្រឹត្តកំហុស ទើបគេដេញចាប់មិនឈប់ឈរដូច្នេះ? ក្ដស្ងួរឈឺប ! គំដងប្ដូរកុងាវចាក់ស្ទាតនាយយ៉ាងរហ័ស

ក្នុងរយៈពេលប៉ុន្មេះ មាណពហាត់ស្ទៀតខ្ញុំប្រចាំត្រូសាគទឹង ជាមួយទឹកភ្លៀងឥតឈប់ឈរ កាលណាម៉ាណពលើកដៃយ៉ឺត ឬ ខ្ទុលទំនងទឹកភ្លៀងបាប់ម្ជុលស៊ុកត្រចៀក ឬ ទាញសក់ក្បាលនាយជាង ម៉្ងោះហើយស៊ឹផានលៃងយ៉ឺតយ៉ាវ ដូចកាលប្រយុទ្ធជាមួយអ្នកស្រីរុនយូក្នុងភោឆ័កញ្ចាស់ទៀតហើយ ត្រានតែឃើញពន្លឺដាវភ្លេក នាយឥតគិតច្រើន ត្រាសដៃបញ្ចេញស្ទៀតទឹដប់ប៊ីឈ្មោះ «គន្ធយក្ខ បាប់ខ្ទាំកដៃប្រុសអាវសជាប់ក្រាម ។

ជននោះលាន់មាត់យ៉ស ! ត្រវាត់ដាវរបោលប្រុស, មាណពឆ្ងៀតពេលប្រើក្បួយដៃផ្ទះ គាត់ឲ្យឡើយបើលានក្រឹក ! ប្ញាក់ក្ដុងចេញឈាមពេញមាត់ព្រួសធ្មេញប្អូនជប់បោលលើក្ដារទូក មាណពឥតស្មានថាស្ទៀតគន្ធយក្ខាកមានភាពកាចសាហាវបែបនេះ កំទៅជាស្រឡាំងកាំងដកជើង ញាប់ ដោយភ័យបារម្ភ ។ សិស្សត្អឹកកកឯទៀតប្រញស្ទុះទៅប្រឡូកដែរ កាលណា ឃើញបងប្អូនត្រូវរបួសយ៉ាងដំណាំ ក្រោមកណ្ដាប់ដៃស៊ឹផានយ៉ាងរហ័សមើលមិនទាន់ដូច្នេះ គេស៊ុំ ដំណេករមៀនខ្លួន និកថា:

-បងប្អូនត្រូមានយុទ្ធសិល្បៈខ្ពង់ខ្ពស់ជាងយើងនៃត្រូវបរាជ័យធាប់រហ័សប៉ុណ្ណោះហើយ យើងចូល ទៅទៀតក៏ឥតប្រយោជន៍ដែរ, គួរជួយកអាសាគាត់សិន ។

ដោយគិតឃើញដូច្នេះទើបគេស្ទុះទៅលើកក្រកងបងប្អូនត្រូមកដាក់ទូកតូចវិញហើយបញ្ជាឲ្យគាត់ឲ្យបត ក្បាលទូកត្រឡប់ក្រោយជាបន្ទាន់ ។ ទូកធំរបស់ទឹងមិនហួសបីចេះតែលឿនទៅមុខ , សម្រែក ដេគ្រោះគិះដៀលគ្រប់បែបយ៉ាងសោតពីទូកតូចមកចូលត្រចៀកស៊ឹផានល្វើយៗ ... មាណពនឹងមើល

ញ្ញាទិន ឈាមក្រហមឆ្អៅលើក្តារខៀន នាយកំយរនេក, ការណិតគេស្ទើរខ្វាចចិត្ត ។ ចង់គុន ដើរចេញមកញញឹមដាក់នាយ ពោលថា:

- បងពិតជាសំដែងស្មៀតត្រឹមត្រូវតាមក្បួនវេតខ្ពោះមែន ! ពូកែណាស់ ។

ស៊ីផានត្រវីក្បាលតប:

- ម៉េចកាលពីមុននាងមិនប្រាប់ខ្ញុំឲ្យដឹងច្បាស់លាស់ផង មិនស្មានថាគ្រាន់តែមួយក្បាច់ធ្វើឲ្យគេហួសដល់ម៉្លឹងសោះ ។ ស្មៀតរបៀបហ្នឹងខ្ញុំឈប់ហាត់ហើយ ។

ចង់គុនចម្លាក់ទឹកមុខ និកថា „បងពិតជាត្លុកទៀតហើយតើ ទើបនិយាយល្ងីល្ងើដូច្នេះ" ។ នាងពោល:

- បើហាត់យុទ្ធសិល្បៈត្រូវរើសរកស្មៀតណាដែលខ្លាំងពូកែ ទើបប្រសើរ ! អម្បាញ់មិញបើបងបញ្ចេញស្មៀតកន្ទុយក្ងោកមិនទាន់ពេល ម៉្លេះសមផ្លែដាវចាក់ចំមុខស្លាដាច់ទៅហើយ ។ បើបងមិនធ្វើឲ្យគេរបួស គេនឹងបណ្តាលឲ្យរបួសបងវិញមិនខាន ! តើបងចូលចិត្តឲ្យគេវាយ ឬវាយគេ ? និយាយតាមត្រង់ទៅ គ្រាន់តែវាយបាក់ឆ្អឹងម៉្យាងមិនជាធ្ងន់ធ្ងរប៉ុន្មានទេ ! ព្រោះការប្រយុទ្ធគ្នាតែងមានរបួស ឬ ស្លាប់អ៊ីចឹងឯង ។ បងបានធម៌សប្បុរសមែន ប៉ុន្តែសត្រូវមិនមែនចិត្តល្អទេ ហើយប្រសិនបើបងត្រូវគេសម្លាប់ទៅ ទោះចិត្តល្អយ៉ាងណាមិនអាចរស់វិញបានដែរ ។

មាណពនៅស្ងៀមមួយសន្ទុះ, តប :

- យកស្រួល នាងគួរបង្ហាត់វិជ្ជាណាមួយឲ្យខ្ញុំ ដែលមិនធ្វើឲ្យគេរបួស ឬស្លាប់ ហើយអាចការពារមិនឲ្យគេវាយខ្ញុំបានផង នោះយើងទាំងអស់គ្នានឹងលើចក្អាកក្អាយដូចមិត្តភក្តិ មិនមែនសត្រូវទេ ។

ចង់គុនញញឹមស្ងួត:

- និយាយតែផ្តាស ! និយាយតែផ្តាស ! អ្នកគុននិយមទាំងឡាយ កាលណាចាប់ប្រកួតប្រជែង តែងប្តូរស្លាប់រស់ជាមួយគ្នាជានិច្ច ។ បងនឹកស្មានថាគេលេងល្បែងបិទពួន ឬលេងជីខ្លាប់ពួនជាក្តី ?

- ខ្ញុំចូលចិត្តលេងល្បែងបិទពួននិងពួនជីខ្លាប់ណាស់ ខ្ញុំមិនចូលចិត្តប្រយុទ្ធប្តូរជីវិតគ្នាទេ ។

ចង់គុនរឹតតែស្អប់កាន់តែខឹងឡើង ។ នាងគំហក :

-បងឯងកុំភ្លើមេន! ហានិយាយស្ដីជាមួយបងឯងច្បាស់ជាស៊ីយមួយជីវិតហើយ!

នាងខឹងពេកឈប់រវល់នឹងនាយហើយចូលទៅក្នុងចុងប្រះខ្ទមដេកភ្ញាម ។ ចិនមិនហួសចិត្តទៀត ខ្មាសពោលថា :

- ឃើញទេ! គានិយាយមានខុសឯណា! ធម្មតាមនុស្សត្លុកលីលាទោះមានតម្រេះខ្ពង់ខ្ពស់យ៉ាងណាក៏នៅតែត្លុកដដែល! គួរសម្លាប់វាចោលឲ្យហើយទៅកុំឲ្យទើសភ្នែកទើសច្រមុះទៀត ។

ចិនគុងគិតថា :

-ប្រសិនបើបងគ្មានទៅតែល្ងីល្ងើអញ្ចឹងរហូតទៅ តើយើងអាចរួមរស់ជាមួយគាត់បាន ឬ ? មិនកើតទេ! ត្រូវតែធ្វើតាមលោកតាសម្លាប់គាត់ចោលទៅប្រហែលស្រួលជាង ។

តែបន្ទាប់មកនាងនឹកដល់ការថ្នាក់ថ្នមល្ហុងលោមប្រកបដោយសំដីផ្អែមត្រជាក់ នៃស៊ុំផាតមុនពេលមានជម្ងឺ ។ ទោះកាលនោះស៊ុំផាតមិនយាយស្ដីរកនាងមួយម៉ាត់ក៏ដោយឲ្យតែសម្លឹងមើលមុខបន្តិចក៏មានសប្បាយរីករាយភ្លេចខ្លួនដែរ ។ លុះបែកឃ្លាតទៅ នាងតែងរឭកគេរហូតដេកមិនលក់បក់មិនល្ហើយ ។ មិននឹកស្មានថា ក្រោយពីមានជម្ងឺ សង្សារដ៏ស្រស់សង្ហាវៃឆ្លាតនេះប្រែក្លាយទៅជាមនុស្សល្ងីល្ងើភ្លើភ្លើតក់ម៉ក់ទុយបុយជ្រូះសោះ ។ គិតច្រើនកាលណា នាងក្រមុំរឹតតែរំជើបរំជួលជ្រួលច្របល់ខ្វល់ខ្វាយស្ដាយស្រណោះកាលណោះ ។ ដំណក់ទឹកភ្នែកហៀរហូរគ្មានស្រាកស្រាន្តលើផែនថ្ពាល់ដ៏ល្អក៏ផង.. ចិនគុងរួលដើមកកាន់តែខ្លាំងឡើង ក៏ប្រញាប់ទាញជួយមកគ្រលុំខ្លួនជិត ។ ចិនមិនហួសចិត្តទៀតល្ហុងលោមរបៀបចាក់ដុបៈ

-ទៅយកអត់ប្រយោជន៍ដែរ ព្រោះទឹកភ្នែកមិនអាចកែឆ្នៃមនុស្សត្លុកឲ្យក្លាយជាមនុស្សបានទេ ។

ចិនគុងតំហាក :

-ប្រសិនបើខ្ញុំយំឲ្យមនុស្សត្លុកល្ងង់ក្លាយទៅជាមនុស្សត្លុកឆ្លាតបានទេ?

ចិនមិនហួសចិត្តតំហាកតបវិញ :

-និយាយផ្ដេសផ្ដាសទៀតហើយ!

ចិនគុងចេះតែយំខ្សឹកខ្សួលនឹកថា :

- មើលឫកពានិងសំដីសំដៅភ្នែកនាងហ្លួន់ជីនាងក្រមុំកកក ដូចជាមិនទាន់ត្រូវបងជានរំលោភបំពានទេ បើបងជានប្រទះនារីដ៏ស្រស់ប្រិមប្រិយបែបនេះហើយ គាត់មិនចេះពោលពាក្យ

លែងខាយល្អន់លោមគេទៀត ឃើញថាគាត់មិនសមជាបុរសដើមទ្រូងប្រាំហត្ថទៀយ , យើងរៀបការជាមួយមនុស្សទុយមុយគ្រមល់ទុចបែបនេះ តើគេសុភមង្គលនឹងគេឃើញដែរ ? ប៉ុន្តែយើងបានសំពះមេឃដីនិងជូនពាទទួលគាត់ជាប្ដីហើយធ្វើម៉េចទៅ ? ។ បើនិយាយពីការរស់នៅវិញ គ្មានសមនឹងប្ដីប្រពន្ធសោះទេ ។ ពេលថ្ងៃគាត់មាននិយាយរក , មើលមុខនឹងប៉ះពាល់សាច់យើងខ្លះ ដល់ពេលយប់គាត់សំកន្តឆ្ងាយពីយើងមួយយោជន៍ គ្មានហ៊ានប៉ះដៃជើងយើងឡើយ កុំថាដល់បេះផ្កាក់ថ្មមល្អន់លោមបពោសអង្អែលដូចស្វាមីគេទាំងពួង ។

នារីគិតចុះគិតឡើងកាន់តែខឹងឆេះឆួល ។ នាងសម្លឹងស្ដាប់មួយស្របក់ឮមាណពដកដង្ហើមវែង ៗស៊ើគ្នាបញ្ជាក់ខ្ញុំរាំងកាយស្ពុកស្ពុក , នារីខឹងក្រោវស្ទុះក្រោកកីងហូតកាំបិតស្នៀតមួយពីដំបូលទូក ដកស្រោមទាកខាំមាត់ សំរេចចិត្តថា:

– បើល្មើទ្រុយ ៗ បែបនេះ កុំទុកឲ្យរស់នាំធ្ងន់ផែនដី !

## វគ្គទី ១៦

## គំនិតនិងប្រាជ្ញា

ចិនតុងដើរលេប ១ ទៅកាន់កន្ទៀទូកព្រាតាចាស់កាន់ចង្កូតដេកលក់ស្រមុកឃ្លូរ១, ឯស៊ីផានក្បែរនោះក៏លក់ស្កប់ស្កល់ឥតដឹងខ្លួនប្រាណដែរ ។ ចិនតុងបន្លឺកន្ទេតោះថា :

-បងផានអើយបង ! នេះជាវាសនារបស់បងទេ ប្រែប្រួលចិត្តគំនិតនឹងរកបច្ចេកិរិយាបែបហ្នឹង ខ្ញុំមិនអាចរស់ជាមួយបងបានទេ , សុំកុំថាខ្ញុំកាក្រក់ ។

នាងលើកកាំបិតប្រុងសំពងលើក្បាលមាណពទៅហើយស្រាប់តែនាងនឹកអាណិតគេទន់ចិត្តវិញភ្លាម លូកដៃចាប់ស្លាអុកកម្ទោះបំបែរមុខយ៉ាងថ្មមមើលម្ដងទៀតជាចុងក្រោយបង្អស់ ។ ពន្លឺព្រះចន្ទចែងចាំងភ្លឺត្របង់លើទូកទាំងមូល បង្ហាញចិនតុងឲ្យឃើញមុខមាណពច្បាស់ គឺនាយដេកលក់ស្កប់ស្កល់មុខញញឹមស្រស់ហាក់កំពុងយល់សប្តិល្អ ។ ចិនតុងរំភើបចិត្តនឹកថាគាត់ជិតស្លាប់ហើយគួរឲ្យអាណិតណាស់, បាំយល់សប្ដិចប់សឹមសម្លាប់ក៏បានដែរ ។

នាងក្រមុំអង្គុយកបក្បាលជង្គង់សម្លឹងមុខមាណពរង់ចាំនាយយល់សប្តិចប់ វែងញញឹមស្រស់ទឹងអាលលើកកាំបិតប្រហារភ្លាម ។ មួយសន្ទុះ នាងឮស៊ីផានមមើថា:

- ចឹងៗ គុងៗ ... ម៉េច ... នាងខឹង? នាងអើយ! ខឹងម្ដងៗ... នាងល្អណាស់..
ខ្ញុំចូលចិត្តមើលមុខនាង ... ព្រោះ នាងល្អ... មើលមួយរយថ្ងៃមួយរយយប់ក៏មិនឆ្អែតដែរ ...
មួយពាន់ថ្ងៃ... ទេ ... មួយម៉ឺនថ្ងៃ .. បីម៉ឺនថ្ងៃ ... ទេៗ .. ប្រាំម៉ឺនថ្ងៃនៅតែមិនអស់ចិត្ត ..
នៅតែមិនឆ្អែត! ...

ចឹងគុងរំភើបចិត្ត បេះដូងលោតក្ដុកក្ដាក់នឹកថា:

- បងបានអើយ! ដេកលក់ហើយនៅនឹកខ្ញុំទៀត! ចេះនិយាយអីចឹងដែរ ម៉េចបងមិន
និយាយឲ្យខ្ញុំស្ដាប់តាំងពីថ្ងៃ ចាំដេកលក់បានមកនិយាយ? ឥ! ទេវតាអើយ សូមឲ្យបងបាន
ស្រះស្បើយពីគេតក្មួចមុខក្មួចក្រោយនេះឆាប់ៗទៅ! ថ្ងៃនោះបងនឹងនិយាយពាក្យពីរោះផ្អែមល្ហែម
ប៉ែបហ្នឹងឲ្យខ្ញុំស្ដាប់មិនខាន ។

ចឹងគុងឃើញមាណពដេកហាលសម្បើម ខោរកវក្ដើង នាងខ្មាចនាយភ្នាក់ស្ទុះចូលទៅក្នុងខ្ទ
យកផ្លុយមកគ្របដណ្ដប់ឲ្យយ៉ាងថ្នម ទើបអង្គុយមើលមុខគេមួយសន្ទុះទៀត ។ នាងលែងចង់
សម្លាប់មាណពហើយ ដើរចូលក្នុងខ្ទមវិញប្រះដេកដាក់ដៃគងថ្ងាស, ស្រាប់តែឮចឹងមិនហួស
ស្រែកដេរ:

- យ៉ស! កណ្ដាសអញ្ជាគ្រហើយ បានសត្វកណ្ដុររត់ចុះរត់ឡើងហ្នឹង! ហើយកំសាក
ណាស់! ចង់សម្លាប់គេតែមិនហ៊ានសម្លាប់ បានការអីធ្វើបៀបហ្នឹង ?

ចឹងគុងនឹកថាជីតាឃើញអស់ហើយ តែនាងមិនរវល់ធ្វើដឹងឮទេព្រោះនាងសប្បាយរីករាយ
ដោយបានឮមាណពមើរបញ្ចាញមិញ ។ រាបាំទាំងប៉ុន្មានលាន់រំពងក្នុងត្រចៀកនាងជានិច្ច
ពិសេសនាងពេញចិត្តត្រង់ ស៊ីផនានពោលថា «មាននាងខឹងម្ដងៗ មុខល្អណាស់», មើលមួយម៉ឺន
ថ្ងៃ, ប្រាំម៉ឺនថ្ងៃក៏មិនឆ្អែត ... នាវឹកដល់នេះសើចខឹក! ព្រោះតិតសព្វ ១ ទៅ «បងបាន»
ឆ្អួត មែនទែនរហូតដេកលក់ ក៏បម៉ើផ្ដេសផ្ដាសដែរ ។

ឧបមាថា យើងរាបរស់បានមួយរយឆ្នាំបំបែកជាថ្ងៃមកឃើញត្រឹមបីម៉ឺនប្រាំមួយពាន់ប្រាំរយទេ ម្ដ
ទៀតគាត់ចង់មើលមុខយើងដល់ទៅប្រាំម៉ឺនថ្ងៃ? នាងព្រួយផងសប្បាយផងដេកឥតលក់សោះរហូ
យាមបួនទើបលង់លក់ទាំងមិនដឹងខ្លួន ។ បានបន្តិចស្រាប់តែឮស៊ីផនានស្រែកឡូឡាឯកនៃខ្ទូកចា

- ចង្រៃណាស់! ចឹងៗ គុងៗ ម៉េចជួយនាងមកនៅលើខ្លួនខ្ញុំវិញ? រាបេះដើរទេដឹង?

ទីនគុនខ្មាសអៀនណាស់ មុខក្រហមទាំងស្រុះមកដល់កន្សែងខូកក្លាមឃើញមាណពកាន់ផ្ទួយនាងស្រែកថា :

- ទីនៗ គុនៗ ! រឿងចំឡែកណាស់ ! ផ្ទួយនេះនៃ .....

ទីនគុនលូកដៃកញ្ចក់ផ្ទួយ ហើយគំហកតិច ៗ :

- ឈប់និយាយទៅ ! គ្រាន់តែផ្ទួយបេះដើរ ក៏ឆោឡោដែរ ។

ស៊ីផណនសួរ :

- ផ្ទួយបេះដើរហើយនៅមិនឲ្យបម្លែកទៀត ! តើដើនរាំនៅត្រង់ណា ?

ទីនគុនងាកទៅម្ខាងឃើញតាចាស់កាន់បង្គីតខូករៀបចេញដំណើរ ៗ ពេលនោះគាត់ងាកមកមើលនាងដែរ, បណ្ដាលឲ្យនារីអៀនខ្មាសលើសដើមក្រហមដល់គុម្ពត្រចៀក ។ នាងគំហកដាក់ស៊ីផណន :

- បងនៅហ៊ាននិយាយទៀតទេ ?

សួរផងលូកដៃប្រុងចាប់ស្ទឹកត្រចៀកផង ។ មាណពខ្លាចឈឺក៏លើកដៃរាំងកាត់ដោយស្វ័យប្រវត្តិ, ទីនគុនបង្វិលដៃចុចបង្កើះនាយវិញ, មាណពយកដៃរាំងទៀតហើយលូកដៃម្ខាងចាប់ស្នាទាងក្រមុំ ។ ទីនគុនគ្រវាត់ផ្ទួយបោលទៅក្នុងយ៉ាងប្រញាប់ ហើយវាយមួយដៃសងវិញភ្លាម ។ នាងដឹងថាស៊ីផណនមានកម្លាំងកាយស្ដុកស្ដម្ភណាស់ទើបប្រយ័ត្នប្រយែងមិនឲ្យប៉ះសាច់នាយយូរទេ ។ តាំងពីទាត់វាយទៅវាយមកមួយសន្ទុះបានសាមសិបស្ទៀត ។ ទីនគុនប្រើកាយវិការញាប់ស្អុក, ស៊ីផណនចំផ្លូងស្នាតើបញ្ចេញស្ទៀតបាប់ខ្ទាំ តាំងដប់ប្រាំបីកាច់តែស្ពាត់ជំនាញឡើង ។

ពេលនេះទីនគុនប្រើស្ទៀតក្រញាំនាគចាប់ប្លាមក្បាលមាណពម្ដង ។ ស៊ីផណនលើកដៃរាំងយ៉ាងប្រញាប់, ទីនគុនដកដៃមិនទាន់ក៏ត្រូវប្រាមតាំងប្រាំរបស់អ្នកកម្លោះកៀសប៉ះដីពចរញ្ជូលរ៉ៃប ! កម្លាំងធាតុស៊ីផណនរត់តាមសន្ទុះខ្យល់ជ្រាបតាមដៃនាងក្រមុំចូលដល់កងកាយធ្វើឲ្យនាងចប់ខ្លួនលែងជាប់ទ្រេតទ្រោតទៅមុខផ្លូលលើផ្ទួយភ្លាម ។ ស៊ីផណនឃើញច្បេះក៏ស្ទុះរឹងទៅក្ដោបផ្ទួយរុំទីនគុនជាប់លើកពារថុកដីសើចហាស ៗ :

- ហេតុអីនាងមួលស្ទឹកត្រចៀកខ្ញុំ ? ប្រយ័ត្នខ្ញុំបោះឲ្យត្រីស៊ីណា៎ !

ទីនគុន ត្រេកអរណាស់ ! ខ្មាសអៀនផងសប្បាយផងនៅក្នុងផ្ទួយ ។ នាងស្រែកសួរតាំង

សំណើចក្អឹកៗ:

- បងហ៊ានឬ ?

- ម៉េចមិនហ៊ាន ? ចាំមើលណា៎ !

ពោលចប់នាយលើកនាងគ្រវែងចាំងផ្លូវលើក្ដារខូកប្រុសហើយ សើចក្អាកក្អាយលោត ថយក្រោ វិញ ៗ ទីងតុងរើបំរះចេញពីផ្លូវដើរតម្រង់កន្លែងខូកទៀត ៗ ស៊ីផណខ្វាចនាងវ៉ា ប្រញាប់ឈរកន្លែកដើងលើកដៃប្រុងស្ទៀតរង់ចាំមុនតែទីងតុងបែរជាងើយមុខសើចហើយបន្ទោសៈ

- ឈប់លេងហើយ! មើលបុកពោះគ្មានសង្ហា , គ្មានសមនឹងអ្នកក្លាហានសោះតែម្ដ ដូចកូនសិស្សថ្នាក់ទី ១២ អីចឹង !

មាណពឆ្លើយ :

- ខ្ញុំមិនមែនអ្នកក្លាហានឯណា ?

- សាធុ ! សាធុ ! បងហាត់ស្ទៀតបាប់ខ្ញុំស្អាត់ជាងខ្ញុំជាគ្រូផង នៅមន្នាក់ខ្លួនដល់ណ ទៀតពេលកបង ? កូនសិស្សនេះ «ឡើបុក» ដល់ហើយ !

ខណៈនោះទីងមិនហួសបីពោលចំអកពីក្បាលខូកមក :

- កុំសរសើរពេកវ៉ើយ ! បេះប៉ុណ្ណឹងមិនមែនទៅប្រកួតប្រជែងជាមួយប៉ាយរ៉ាន់ផានបានទេ, ខ្វះបទ្ពិនណាស់ ៗ ,

ទីងតុងតប :

- លោកតាអើយ ! បងណានហាត់តាប់បេះតាប់ចំណាស់ រៀនហើសម៉ឺង ១ បើបានទៅ មួយលោកតាមួយឆ្នាំ ឬ កន្លះឆ្នាំ ច្បាស់ជាសក្ដិសមធ្វើទៅប្រសាទីងមិនហួសបី ហើយ នោះម៉ បានឡើងជាកំពូលអ្នកគុនមិយមក៏ដោយ ៗ លោកតាលែងអាម៉ាស់មុខហើយ !

ទីងមិនហួសបីសើច ហេស ៗ :

- សំដីដែលទីងមិនហួសបីពោលមកហើយ មិនកាចប្រែប្រួលទេ ៗ តាប្រាប់ទៅ ហើយតើ ! បើរ៉ាចង់បានទៅធ្វើប្រពន្ធ, តាមិនបង្អាក់បងៀនរ៉ាជាដាច់ខាត ! ទីពីររ៉ាត្រូវទៅ ប៉ាយរ៉ាន់ផានប្រយុទ្ធគ្នាឲ្យដឹងឈ្នះចាញ់ ៗ តាកំណត់ពេលដប់ថ្ងៃណា៎ ! មិនមែនកន្លះឆ្នាំឬមួ ឆ្នាំទេ ៗ ផ្សូវសល់ប្រាំថ្ងៃទៀតប៉ុណ្ណោះ ពេលប្រមក់នេះនឹងត្រូវបាត់បង់ជីវិតហើយ, ឯង

និយាយវែងឆ្ងាយពេក ។

ចិនគុនគ្រវាក់ខ្លួនស្រែក យប់មិញនាងបង់សម្លាប់មាណពផ្ទាល់ដៃ តែថ្ងៃនេះនាងមិនដាច់ចិត្តឲ្យដីតាប្រហារសង្សារទេ ។ បើលោកតាមិនកែប្រែសំដី, តើឲ្យនាងគេចយ៉ាងណាទៅវិញ ?

នារីគិតមិនលេចសោះ នៅសល់តែមធ្យោបាយមួយគត គឺបន្តុំស៊ីផានឲ្យហាត់ស្ទៀតបាច់ខ្លាំង តាំងដប់ប្រាំបី សាចុះសាឡើង ឲ្យមាណពស្ទាត់ជំនាញ និងរហ័សរហួនមែនទែន ។ សល់ពីនោះត្រូវឲ្យនាយទទួលទានបាយ និងដំណេកច្រើន ដើម្បីមានកម្លាំងកាយជាជំនួយ ។ ស៊ីផានគាន់តែថ្មើក គាចប្រយុទ្ធជាមួយចិនគុនបានស្មើគ្នា ។ ដល់ថ្ងៃទីដប់ប្រាំបីចិនមិនហួសបីត្រៃហោមតាំងព្រឹកព្រលឹម :

- នៅសល់តែបីថ្ងៃទៀតទេរ៉ុយ ។

ចិនគុនឆ្លើយ:

-លោកតាកុំភ័យ ។ តាមខ្ញុំមើលដូចជាមិនពិបាកទេ ។ លោកតាចង់ឲ្យបងផានទៅប្រយុទ្ធនឹងប៉ាយរ៉ាន់ជានតាល់តែឈ្នះឬ ? ខ្ញុំហ៊ានទាយថាគុនដាវរបស់ប៉ាយរ៉ាន់ជានពូកែណាស់ តែគាប៊ុហ្នឹងមិនអាចយកប្រៀបលើបងផានបានទេ ព្រោះបងផានហាត់ស្ទៀតបាច់ខ្លាំងប្រចាំគ្រួសារចិនស្ទាត់ជំនាញណាស់, ថែមទាំងមានកម្លាំងក្រៀវក្រោះផង លេងតែដៃទទេក៏អាចដណ្ដើមការុធពីប៉ាយរ៉ាន់ជានបានដែរ ។ លោកតាអើយ ! បើបងផានដណ្ដើមដាវប៉ាយរ៉ាន់ជានបានមក, លោកតាថាគាត់ឈ្នះដែរ ?

ចិនមិនហួសបីពោលចំពេក :-

-ហាស ៗ ! មីចៅស្រីឯងកុំនិយាយឆ្ងាយពេក ! គម្រះប៉ុណ្ណឹងហ៊ានថាដណ្ដើមដាវពីដៃអ្នកក្លាហានវិសុទ្ធបានផងឬ ? កុំយល់សប្តិទាំងថ្ងៃរ៉ុយ ! សូម្បីតាក៏មិនប្រាកដដណ្ដើមការុធពីជនត្រកូលប៉ាយនោះបានដែរ ។

ចិនគុនបួញមាត់ :

- បើគង់តែស្លាប់ដែលខ្ញុំយល់ថាទៅដណ្ដើមដាវអ្នកក្លាហានវិសុទ្ធ សាកមើលសិនទើបមានសង្ឃឹម ។ ម្យ៉ាងទៀតស្លាប់ដោយសារដណ្ដើមការុធគេប្រសើរជាងស្លាប់ដោយសារដីតាក្អេក ! អូលោកតា ! ក្នុងរយៈពេលដប់ថ្ងៃបើគេប៉ាយរ៉ាន់ជានមិនឃើញធ្វើម៉េចទៅ ? លោកតាទម្លាក់កំហុស

លើបងណានដែរហ្ន៎ ?

– យីអើ! ដប់ថ្ងៃគឺដប់គត់តែម្តង, មិនបាច់និយាយច្រើនទេ ។ តាប៉ុប៉ាយនៅម្តុំហ្នឹង, គេឃើញថ្មមិនឃើញកំពុងដប់ថ្ងៃនេះដែរ , បើតាប្រមក់នេះវ៉ាយមិនឈ្នះគេ, តាសម្លាប់វាចោលភ្លាម!

– យី! នៅសល់បីថ្ងៃសោះទៅគេឯណាលោកតា! លោកតា ... មិនព្រមគេខុសត្រូវសោះហើយ!

– ហាស ៗ ... ចីងមិនហួសបីចេះគេខុសត្រូវពីកាលណា ? ចៅឯងស៊ើបឲ្យសព្វគិតគូរមើល ? ចីងមិនហួសបីចេះគេខុសត្រូវនឹងគេទេ ?

ក្នុងថ្ងៃទីប្រាំបីទីប្រាំបួននោះចីងគុងខំបង្ហាត់បង្ហាញស្មៀតសិក្សាស្រ្តប់ខ្សែខ្យល់, ស្មៀតខ្វះឆោបកូនមាន់, លូកដៃយកមិនស្មៀតលូកហោះឡើយកទ្រព្យដែលសុទ្ធជាស្មៀតសំខាន់ដើម្បីដណ្តើមការផលត្រូវៗ

ថ្ងៃទីប្រាំបួនចីងមិនហួសបីសម្ងំមុខបាណតាដោយញញឹម, ពន្លឺក្នុកគាត់ចាំងផ្លេកៗយ៉ាងចំឡែកៗ ចីងគុងយល់ថាថ្ងៃទីដប់លោកតាច្បាស់ជាសម្លាប់ស៊ីផានចោលដូចពាក្យគាត់ថាហើយ ព្រោះមិនដឹងគេប៉ាយវ៉ាន់ផានឯណាទេ បើចន្ទេចចំលូងលោយមិនបែបនេះ ។ ពីរថ្ងៃទៀតខំហាត់រៀនឲ្យឈ្នះប៉ាយវ៉ាន់ផានឃើញថាអត់ប្រយោជន៍ទេដឹង ?

ចីងគុងខំប្រកួតយុទ្ធសិល្បៈជាមួយស៊ីផាន ពេកពេកសៀលជ្រៀតជ្រុលហត់គយូរមុខក្រហមច្រឿនៗ បែកញើសជោកថ្ពាល់ ។ នាងលូកយកកូនកន្សែងជូតមុខហើយស្ងាបហាមពោលថា:

– ឥឡូវនេះហើយមើបក្តៅស្អុះម៉េះហ្ន៎ !

ចីងគុងអង្គុយជិតស៊ីផានផ្អែកខ្នងនឹងដញ្ចាំងទូក បង្អួលសត្វស្វាបមួយគូហែលហែបលើផ្ទៃទឹក ។ នាងសួរ :

– បងផានមើលបក្សាបក្សីមួយគូនេះចុះ ៗ វ៉ានាំគ្នាហែលលេងយ៉ាងសប្បាយ ។ ចុះបើមានព្រាញក៏ហើរមកត្រូវវ៉ាឈ្មោលស្លាប់ភ្លាមទៅ, មេញីកំព្រាខ្វាចផ្សាណាស់មែនទេ ?

ស៊ីផានតបវិញ:

– កាលខ្ញុំបាញ់សត្វក្នុងព្រៃភ្នំ, បានចាប់មួនៗមិនដែលមើលថាឈ្មោលឬញីទេ ។ បើនាងនិយាយអ៊ីចឹងខ្ញុំលែងហ៊ានបាញ់សត្វឈ្មោលហើយខ្វាចសត្វញីកំព្រាខ្វាចផ្សា ។

ចីងគុងដកដង្ហើមធំនឹកថា បងផានពិតជាវិលខួរក្បាលលីលាមែន !

នាងដោកឡុយពេកលែងនិយាយតទៅទៀត ទម្លាក់ក្បាលលើស្មាមាតាពុតធេចក្នុកលង់លក់ទៅ ។

ស៊ីផានពោលៈ

- ទីនៗ ទុនៗ ! នាងហត់ណាស់, អស់កម្លាំងណាស់, ចាំខ្ញុំនាំចូលទៅគេងក្នុងទូកណា !

ទីនទុនឆ្លើយតិចៗៈ

- ទេ ! ខ្ញុំចូលចិត្តគេងទីនេះដែរ ។

មាណពមិនហ៊ានជំទាស់ក៏បណ្ដោយឲ្យនាងដេកលក់លើស្មាដោយសុខសាន្ត ។ នារីដកដង្ហើមវែងៗ, វាយោបក់ផាត់សក់ក្បាលនាងបកប៉ះមុខមាណពរសើបៗ ក្លិនទីនទុនក្រអូបកាយៗដល់ទ្រូងមុះនាយ ។ កំពុងតែអណ្ដែតអណ្ដូងស្រាប់តែបានដូចជាសម្លេងតូចឆ្មាររត់ជ្រៀតជ្រែកក្នុងរន្ធត្រចៀកនាយពុតិចៗសឹងស្ដាប់មិនឮថាៈ

- ខ្ញុំនិយាយជាមួយបង,បងត្រូវស្ដាប់ តែហាមដាច់មិនឲ្យងក់ក្បាល ឬ ពោលពាក្យអ្វីតបវិញទេ ។ ត្រូវធ្វើមុខធម្មតា ធ្មេចភ្នែកសម្ងំស្ដាប់ ដកដង្ហើមមួយៗ ដើម្បីជួយបំបិទសម្លេងខ្ញុំ ។

មុនដំបូងស៊ីផានព្រឺក្បាលខ្លាចស្មានថា ទីនទុនមមើមមាយផ្ដេសផ្ដាស ។ ដល់លបមើលនាងម្ដង នាយឃើញទីនទុនបើកភ្នែកម្ខាងម្ដងហើយបិទទៅវិញ រួចបើកបិទពីរដងទៀតទើបបិទហូត ។ ភ្លាមនោះនាយនឹកឃើញថាៈ

- នាងចង់និយាយជាមួយយើងមិនឲ្យលោកតាឮទេតើ ! នាយយល់ដូច្នេះទើបធ្វើជាស្ងាបហាមពោលថាៈ

- ងុយដេកណាស់ !

នាយធ្មេចភ្នែកធ្វើជាដេកលក់ភ្លាម ។ ទីនទុនត្រេកអរណាស់នឹកថាៈ

- បងឆាប់មានគតិលីលាឯណា ? គ្រាន់តែប្រាប់ម្ដង គាត់យល់ភ្លាម ។ អើហ្ន៎ ! គាត់ធ្វើដេកលក់សមណាស់តើ !

នាងចាប់ផ្ដើមពោលតិចៗប្រាប់ស៊ីផានៈ

- លោកតាថា បងអន់ខ្សោយណាស់ហើយគ្មានលីលាផងមិនសមធ្វើចៅប្រុសាគាត់ទេ ។ ស្អែកនេះជាថ្ងៃចុងក្រោយដែលគាត់ប្រាប់ថាកំណត់ឲ្យបងសម្លាប់ប៉ាយរ៉ាំងផាន ។ បើរកប៉ាយរ៉ាំងផានមិនឃើញ ហើយបងគ្មានសមត្ថភាពវាយឈ្នះតាប៉ុប៉ាយផងគឺបងត្រូវស្លាប់ជាដាច់ខាត ។ ឥឡូវសល់មធ្យោបាយតែមួយគត់គឺពីរនាក់ប្ដីប្រពន្ធយើងរំដោះខ្លួនទៅរស់ក្នុងព្រៃកុំឲ្យ

លោកតាកេឃើញទៀត ។

ស៊ីផានស្តាប់ចប់នឹកធ្ងល់ថា ហេតុអីទៅស្បៀមៗលោកតាបងសម្លាប់យើងហ្ន៎ ! ចិងៗគុងៗនេ
ក្មេងណាស់ គ្រាន់តែលោកតានិយាយលេងប៉ុណ្ណឹងក៏ភ័យដែរ ។

ប៉ុន្តែបើនាងបងបបួលទៅតួចក្នុងព្រៃកុំឲ្យលោកតាកេឃើញដូចជាសប្បាយម៉្យាងដែរ ។

ចិងគុងពោលបន្ត :

–បើយើងបបួលគ្នាតែឡើងគោកខ្ញុំហ៊ានតាយថាលោកតាដេញតាមមិនទាន ។ សូមបងចាំណា
ដល់ពេលយាមបី ខ្ញុំធ្វើជាមមើស្ទុះទៅទបលោកតាយំស្រែកថាលោកតា! លោកតាសុំកុំសម្លាប់បងផាន
ពេលនោះបងត្រូវស្ទុះទៅជួយខ្ញុំដោយដៃស្តាំប្រើស្បៀត « ក្រញាំខ្លា » ចាប់ជីពចរលើខ្នងលោកតាដៃឆ្វេ
ប្រើស្បៀត « បេះផ្កាបោលស្មៅ » ចាប់ចង្កេះគាត់ពីក្រោយឲ្យជាប់ ។ តែបងកុំភ្លេចណា!
ចាំខ្ញុំស្រែកឃាត់ថាកុំសម្លាប់លោកតា បើបងចាប់ចង្កេះ ហើយចាប់តាមស្បៀតបេះផ្កាបោលស្មៅ
ខ្ញុំចាប់ទបគាត់ជាប់ហើយ បងកុំភ័យលោកតាឥតមានដៃមកទប់ទល់ទេ ។ ម៉្យាងទៀតបងមា
កម្លាំងស្ទុកស្ទម្ភណាស់ កាលណាចុចជីពចរលោកតាហើយលោកតាកំរើកឥតរួចទេ ។

ស៊ីផានស្តាប់បណ្តើរនឹកបណ្តើរ:

–ចិងៗគុងៗកំប្លែងណាស់តើ! ហ៊ានបបួលយើងប្រឡែងលេងជាមួយលោកតាផង, មិនដឹងតើលោ
ខឹងឬទេ? ល្អហើយ! បើនាងបងសប្បាយយើងជួយនាងបន្តិចចុះ ។ នាងនៅក្នុងនេះងប់សប្បា
ណាស់យើងក៏ខានសប្បាយយូរដែរ ។

ចិងគុងពោលបន្ត :

–ដៃដែលបងចាប់ខ្ញុំស្ទើរក្ស័យជីវិតណា! ឥឡូវបងលូកដៃឆ្វេងស្ទាបជីពចរខ្នងខ្ញុំមើលតើស្បៀ
ក្រញាំខ្លាយ៉ាងណាដែរ?

ស៊ីផានធ្មេចភ្នែកដដែលហើយលើកដៃឆ្វេងអង្អែលជីពចរខ្នងនាងក្រមុំស្រាលៗ ! ចិងគុងបន្ត

– ត្រូវហើយ ! ក្នុងពេលនឹងត្រូវសំគាល់ជីពចរឲ្យបានត្រឹមត្រូវនិងរហ័សរហួន ! ចំណែ
ខ្ញុំខំប្រឹងចាប់ទបយ៉ាងពេញទំហឹងព្រោះបើបង្អង់យូរបន្តិចគាត់ច្បាស់ជាដឹងខ្លួន, គ្រវាត់ខ្ញុំចោល ហើ
ពេលនោះបងពិតជាចុចជីពចរគាត់មិនបានឡើយ ! ឥឡូវបងស្ទាបជីពចរចង្កេះខ្ញុំមើលនៅកន្លែងណា
ឯស្បៀតបាចផ្កាបោលស្មៅ គ្រាន់តែបញ្ចេញបេនិងបន្តុលដៃបញ្ចូលកម្លាំងតាតុទៅបានហើយ ។

មាណពចម្នាក់ដៃសន្ធឹម ៗ យកម្រាមពីរផ្ដិលជីពចរចង្កេះនាងថ្នម ៗ ដោយពុំមានបញ្ចូលកម្លាំងណាមួយ ៗ តែចិនតុងជាស្រីក្រមុំឆាប់ខ្មាសណាស់ គ្រាន់តែម្រាមដៃនាយប៉ះចង្កេះ នាងអត់ទ្រាំមិនបានសើចក្អាកក្អាយស្រែកខ្លាំង ៗ :

– កុំធ្វើផ្ដេសផ្ដាស !

ស៊ីផានក៏សើច ហាំ ៗ ហាំ ៗ ដែរ បន្ទាប់មកចិនតុងចាក់ចង្កេះនាយវិញ ៗ អ្នកទាំងពីរប្រឡែងគ្នាសើចរមួលខ្លួន ក្លួចក្លៀនសប្បាយធ្វើដេកលក់សេសលើន !

ពេលប្រលប់លុះទូកអែបច្រាំងតាចាស់កាប់ចង្កូតកាច់ចបស្រាចៀនយ៉ាងប្រញាប់ ៗ ចិនតុងស្ដីមវាចា :

– បងផានយើងទៅដើរលេងលើគោកឬ ?

មាណពនឹកក្លួលផឹកដៃនាងក្រមុំទាំងក្ដីសប្បាយ ៗ ភូមិនេះមានអ្នកស្រុកតិចណាស់ភាគច្រើនជាអ្នកនេសាទ ... ទាំងពីរប្រាណដើរផុតផ្សារ ស្ងាត់ជ្រងំពុំមានមនុស្សម្នាក់ឡើយ ៗ

ស៊ីផានឧទាន :

លោកតានៅសម្រាន្តក្នុងទូក ឥឡូវនេះយើងរត់ទៅមិនរួចទេឬ ?

ចិនតុងគ្រវីក្បាល :

– មិនអីយទេ ទោះយើងរត់បានប្អូនជប់ប្ដូរយោជន៍ក៏គាត់នៅតែដេញតាមទាន់ដែរ !

ខណៈនោះស្រាប់តែឮសម្លេងខ្សាវ ៗ មកពីក្រោយ :

– ទុកជាពួកឯងរត់បានមួយពាន់មួយម៉ឺនយោជន៍ យើងនៅតែដេញតាមទាន់ដែរ !

មាណពនិងចិនតុងបែរក្រោយ ឃើញបុរសការសពីរនាក់ដើរចេញពីគល់ឈើមួយដើម ៗ ម្នាក់ខ្ពស់ម្នាក់ទាបឈរសម្ងំនឹងមកក្នុងក្រសែភ្នែកដ៏កាចសាហាវ ៗ ស៊ីផានស្គាល់ច្បាស់បុរសការសទាំងពីរនេះគឺហ៊ួរវ៉ន់ យានឌិនមិនវ៉ន់ហ្វូនៃក្រុមភ្នំទឹកកក ៗ នាយស្រឡាំងកាំងបន្តិច ហើយភ្ញាក់ភ័យញាក់ញ័រណាស់ ៗ ព្រោះនៅពេលសមាជិកនៃក្រុមភ្នំទឹកកកដឹងថាមាណពនៅលើទូកហើយក៏ចាត់គ្នាពីរនាក់មកចាប់តែត្រូវនាយវាយរបួសម្នាក់រត់ត្រឡប់ទៅវិញ ៗ

ប៉ាយវ៉ន់ផានបញ្ជាឲ្យប្អូនរួមគ្រូវាយស្ទាក់ជាពីរពួក មួយពួកតាមផ្លូវទឹក, មួយពួកតាមផ្លូវគោក ៗ ហ៊ួរវ៉ន់ យានឌិនមិនវ៉ន់ហ្វូបំផាយសេះតាមផងទន្លេរហូតមក មិននឹកស្មានថាបានជួបប្រទះស៊ីផាន

នៅទីប្រជុំជននេះសោះ ។ ហ៊ូវ៉ាន់យានជាមនុស្សចេះគិតវែងឆ្ងាយ គាត់ខ្លាចក្រែងពួកខ្លួនពីរនាក់វាយមិនឈ្នះអាក្មេងត្រកូលស៊ឺ ក៏ប្រុងដកព្រួញដើម្បីបាញ់ទៅលើអាកាសជាសញ្ញាប្រាប់ឲ្យបងប្អូនទាំងអស់មកជួយ តែមិនវ៉ាន់ហ្វូដែលមានចិត្តឆេវឆាវអត់ទ្រាំមិនបានក៏ស្ទុះចេញពីកន្លែងលាក់ខ្លួនទាំងទទឹងទិស ។ ទីងគុងបារម្ភណាស់ដែរនឹកថាអ្នកទាំងពីរជាសិស្សភ្នំទឹកកក មិនដឹងប៉ាយវ៉ាន់ជានមកដែរឬទេ ? ប្រសិនបើប៉ាយវ៉ាន់ជាននៅទីនេះហើយ លោកតាបង្ខំឲ្យបងធានប្រយុទ្ធនឹងគាត់ច្បាស់ជាពិបាកមិនខាន ។ នាងសម្លឹងបុរសទាំងពីរ គំហកថា :

– និយាយតែគ្នាយើងទេ ម៉េចពួកឯងមកលាយឡំដែរ ? បងធាន, យើងត្រឡប់ទៅខ្ទមវិញ !

មាណពងក់ក្បាលបែរខ្លួនត្រឡប់ទៅវិញភ្លាម ។ មិនវ៉ាន់ហ្វូធ្លាប់តែប្រមាថសិស្សរូបនេះតាំងពីដើមមកគាត់នឹកថា វាបានហាត់រៀនយុទ្ធសិល្បៈនៅលើភ្នំទឹកកកមែន ប៉ុន្តែគ្មានបានផលប៉ុន្មានទេ ប្រសិនបើយើងចាប់វាយកទៅជូនលោកបងប៉ាយប្រាកដជាបានរង្វាន់ក្រាស់ក្រែល ហើយពេលនោះនឹងមានឈ្មោះបោះសម្លេងពេញពិភពគុនមិនខាន ” ។ គិតរួចគាត់គំហក :

– ទៅណា ? អាក្មេងត្រកូលស៊ុំឈប់សិន ! មកតាមយើងភ្លាម !

គាត់ស្ទុះចូលទៅ យារដៃឆ្វេងចាប់ស្មាមាណព ស៊ីផានផ្អៀងខ្លួនបញ្ចេញស្នៀតចាប់ខ្វាំដែលទីងគុងបង្ហាត់ ដោយលើកដៃវេកាត់ស្នៀតវាយលុករបស់សត្រូវ ។ មិនវ៉ាន់ហ្វូក៏មិនអន់ដែរគាត់ចាប់ខុសក៏លើកជើងទាត់ពោះស៊ីផានវិញ ។ មាណពឃើញគេលើកជើងទាត់ដូច្នេះមិនដឹងគិតធ្វើយ៉ាងម៉េច ការពារខ្លួនយ៉ាងណា ព្រោះមិនធ្លាប់ហាត់ស្នៀតរបៀបនេះសោះ ។ គួរបញ្ជាក់ថាកាលទីងគុងបង្ហាត់ស្នៀតចាប់ខ្វាំឲ្យនាយនោះ តាមពិតគ្រាន់តែបង់ឲ្យមាណពចេះស្ទាត់នូវស្នៀត “ក្រញាំខ្លា” និង “ចាប់ផ្កាបោលស្ទៅ” ប៉ុណ្ណោះ តែដើម្បីចៀសវាងកុំឲ្យលោកតាសង្ស័យនាងក៏បង្ហាត់ទាំងជប់ប្រាំបីស្នៀតទៅ ដោយគ្មានបង្រៀនរបៀបទប់ទល់នឹងការទាត់ជាក់ទេ ។

ប៉ុន្មានថ្ងៃនេះអារម្មណ៍ផ្តោតលើតែស្នៀតក្រញាំខ្លានិងចាប់ផ្កាបោលស្ទៅប៉ុណ្ណោះ ម៉្លោះហើយនៅពេលអាសន្នមាណពក៏ប្រើស្នៀតទាំងពីរភ្លាម ។ ពេលនេះមិនវ៉ាន់ហ្វូឈរកៀកនៅខាងមុខនាយ មិនអាចបញ្ចេញស្នៀតទាំងពីរបានទេ ។ មាណពតាល់ប្រកមិនរវីរវល់ឲ្យស្នៀតឬក្បាច់ស្របតាមក្បួនខ្នាតយុទ្ធសិល្បអ្វីទេ នាយប្រញាប់ទន្ទ្រាំជើងស្ទុះលោតទៅក្រោយខ្នងដៃគូភ្លាម ។ ដោយកម្លាំងជាតុស្ទុកស្តុកសម្តនាយអាចបង្វិលខ្លួនបានរហ័សរហួនរកស្នាមមិនត្រូវជាហេតុញ៉ាំង ឲ្យគេចៀសផុតពី

សន្ទុះជើងរបស់សិស្សក្ដីទឹកកកយ៉ាងឆាយ ។ មាណពលូកដៃស្ដាំប្រើស្នៀតក្រញាំខ្លាចុចជីពចរខ្ទង់ ឯដៃឆ្វេងប្រើស្នៀតចាប់ផ្កាបោលស្មៅចុចជីពចរចង្កេះព្រមទាំងបញ្ចេញកម្លាំងធាតុធ្វើឲ្យរាងកាយដៃគូទន់ផ្លូលប្រុស !

ហ៊ូវាន់យានប្រុងនឹងចូលមកជួយទៅហើយតែលុះឃើញស៊ឺផានប្រើស្នៀតចំឡែកចុចជីពចរប្អូនរួមគ្រូ គាត់កិតភ័យខ្លាំងពេកដកដាវមិនទាន់ក៏ក្ដាប់ដៃដាល់ចង្កេះមាណពផាំង ។ គាត់ប្រើកម្លាំងផល់ទៅជប់គាត់ដើម្បីជួយមិនវាន់ហូតែត្រូវសូរក្រាក! គាត់ទទួលការម្ចណ៍ឈឺចាប់អនេកដោយដៃស្ដាំត្រូវបាក់ជាពីរបំណែកស៊ឺផានគ្រាន់តែឈឺចាប់ត្រង់ចង្កេះបន្តិចប៉ុណ្ណោះ ។ នាយដកដៃពីរាងកាយមិនវាន់ហូវិញ ឃើញគាត់មួលខ្លួនមួយកន្លែងមិនកម្រើកសោះក៏នឹងចាប់ស្លាប់បែរមុខ ។ គាត់បើកភ្នែកក្រឡេតសម្លឹងមកដោយមានទឹកមុខគួរឲ្យព្រឺខ្លាច ។ មាណពភ្ញាក់ព្រើតស្រែកថា :

- អ៊ីយ៉ូយ ! វីរហើយចឹងៗ គុងៗ គាត់.. ម៉េចគាត់រួញសរសៃអ៊ីចឹង ឬមួយ.. ឬមួយគាត់ស្លាប់ហើយ ។

ចឹងគុងសើចក្អាកក្អាយ :

- បងផាន ! ពីរស្នៀតអម្បាញ់មិញបញ្ចេញបានត្រឹមត្រូវណាស់ តែរលះរលាំងពេកគ្មានបុកពជាអ្នកក្លាហានសោះ ! គាត់មិនស្លាប់ទេគ្រាន់តែពិការអស់មួយជីវិតប៉ុណ្ណោះ ចាប់ពីថ្ងៃនេះទៅអវយវៈរបស់គាត់កម្រើកលែងរួចទៀតហើយ ។

មាណពរឹតតែភ្ញាក់ភ័យខ្លាំងឡើង , លូកដៃជួយគ្រាហ៍មិនវាន់ហូហើយពោល :

- សូម... សូមអភ័យទោសផងចុះ ! ខ្ញុំ... ខ្ញុំមិនមានចិត្តចេតនាចង់វាយលោកទេ តើ... តើគិតធ្វើម៉េចទៅហ្ន៎ ? ចឹងៗគុងៗ តើមានវិធីណាអាចព្យាបាលគាត់បាន ?

ចឹងគុងដកដាវពីចង្កេះមិនវាន់ហូ ហើយប្រាប់ :

- បើបងមិនចង់ឃើញគាត់រងទុក្ខវេទនាយូរ បងសម្លាប់គាត់ចោលភ្លាមទៅ !

មាណពរាដៃហើយគ្រវីក្បាល :

- មិនបានទេ ! មិនបានទេ !

នាយសែនភ័យរំភើបផ្លូលឈរសម្រក់ទឹកភ្នែកតក់ៗ ។ ហ៊ូវាន់យានស្រែកគំហក :

- អាក្លួនបិសាចទាំងពីរនេះបោកបាចមែន ! ឯងដឹងទេថាសិស្សក្ដីទឹកកក សុខចិត្តស្លាប់មិន

ព្រមឲ្យគេប្រមាថមើលងាយទេ ។ ពេលនេះយើងធ្លាក់ក្នុងកណ្តាប់ដៃពួកឯងហើយ ចាប់សម្លាប់ភ្លា
មក ។

-មាណពខ្លាចក្រែងទីងតុងសម្លាប់មិនរង់យានក៏ប្រញាប់កញ្ឆក់ដាវពីដៃនាងហើយដោតដាប់ទីងដី

នាយបបួល:

- ទីងៗតុងៗ,ពួកយើងចាប់ត្រឡប់ទៅវិញ ។

ពោលហើយទាញដៃនាងក្រមុំត្រឡប់ទៅទូកវិញភ្លាម ។ ទីងតុងសើច :

--អ្នកគុខនិយមទូទៅតែងពោលថានាយក្រុមស៊ីនៃក្រុមឈានល្អមានចិត្តកាចសាហាវសម្លាប់មនុស្ស មិនព្រិចភ្នែកទេ ហេតុអ្វីពេលនេះមានធម៌មេត្តាចំពោះសត្រូវម្ល៉េះ ? បងធានឿងអម្បាញ់មិញស្លូបប កុំប្រាប់លោកតាណា ។

អ្នកកម្លោះតប :

-ខ្ញុំមិនប្រាប់ទេ ។ នាងថាគាត់នឹងក្លាយទៅជាមនុស្សពិការមែនឬ ?

-បើបងចុចជីពចរពីរកន្លែងហើយនៅតែមិនអាចធ្វើឲ្យគាត់ក្លាយជាមនុស្សពិការទៀត តើស្នៀ ចាប់ខ្លាំនៃត្រកូលទីងរបស់យើងមានប្រយោជន៍អ្វីទៀត ?'

-បើអញ្ចឹងបន្តិចទៀតនាងឲ្យខ្ញុំទៅចាប់លោកតាមែនទេ ?

ទីងតុងសើចស្រស់ស្រាយ :

-បងចំកួតអើយ ជនកំសាកនៃក្នុងទឹកកកម៉ែនអាចប្រៀបផ្ទឹមនឹងលោកតាបានទេ ខុសគ្នាឆ្ងាយណា ដូចមេឃនិងដី ។ ប្រសិនបើបងចុចជីពចរគាត់ពីរកន្លែងហើយចម្រើនកម្លាំងធាតុបន្ថែមទៀតនោះ យ៉ា ច្រើនអាចធ្វើឲ្យគាត់តាំងដៃជើងរើមិនរួចពីរបីម៉ោងប៉ុណ្ណោះ មិនអាចបណ្តាលឲ្យគាត់ក្លាយជាមនុ ពិការបានឡើយ ។

ស៊ីផាននឹកភ័យក្តុកក្តាក់មិនវាច ។ ត្រឡប់ទៅដល់ទូកវិញឃើញតាដែលកាប់ចង្កូតទូ ដាំបាយឆ្អិនស្រេច ។

នាយបរិភោគបាយបានតែកន្លះចានក៏លេបលែងរួច ។

**(នៅមានត)**

ដំកល់ទុកតាមលេខ ៣២៣ ចុះថ្ងៃទី ២៨-៩-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers